**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ..១៨៥៧៤....អពដ

L202506130023TD3518

ថ្ងៃអង្គារ ៧រោចខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនាឆ្នាំ២០២៥

# សេចក្តីណែនាំ
## ស្តីពី
## ភាតព្វកិច្ចសារពើពន្ធចំពោះបុព្វលាភភាគហ៊ុន

អនុលោមតាមមាត្រា៧ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងកថាខណ្ឌទី៣ នៃប្រការ៩ នៃប្រកាសលេខ ៥៧៨ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីពន្ធលើប្រាក់ចំណូល បានកំណត់ថា ប្រាក់ចំណូលជាប់ពន្ធ គឺជាចំនួនលម្អៀងរវាងតម្លៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទ និងនាពេលបើកនៃរយៈពេលមួយដែលលទ្ធផលក្នុងរយៈពេលនោះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់គិតពន្ធ ដោយត្រូវដកចេញនូវឧបហារិត និងបូកចូលនូវរាល់ការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬការកាត់យកមុនដែលម្ចាស់សហគ្រាសបានធ្វើនៅក្នុងគ្រា។ ឧបហារិតទោះជាប្រាក់ឬជាវត្ថុក្តី មិនមែនជាប្រាក់ចំណូលជាប់ពន្ធទេ។

កន្លងមក អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្កេតឃើញថា សហគ្រាសមួយចំនួនបានលើកឡើងអំពីភាពមិនច្បាស់លាស់ក្នុងការបំពេញកាតព្វកិច្ចពន្ធលើប្រាក់ចំណូលពាក់ព័ន្ធនឹងបុព្វលាភភាគហ៊ុន (Share Premium) ដែលជាចំនួនទឹកប្រាក់ដែលសហគ្រាសទទួលបានលើសពីតម្លៃចារឹក (Par Value) នៃភាគហ៊ុន នៅពេលដែលសហគ្រាសបន្ថែមដើមទុនតាមរយៈការបោះចេញភាគហ៊ុនថ្មី (Share Subscription)។ ក្នុងគោលបំណងឱ្យមានភាពច្បាស់លាស់ក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធិភាព អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម៖

១- បុព្វលាភភាគហ៊ុន គឺជាការបន្ថែមទុនឬជាឧបហារិតរបស់ភាគហ៊ុនិកចូលទៅក្នុងដើមទុនរបស់សហគ្រាស និងមិនមែនជាប្រាក់ចំណូលជាប់ពន្ធទេ។

២- មូលធនភាគហ៊ុន និងបុព្វលាភភាគហ៊ុននៃភាគហ៊ុនថ្មី ត្រូវបង់ចូលទៅក្នុងសហគ្រាសទាំងស្រុង និងត្រូវកត់ត្រានៅក្នុងបញ្ជីគណនេយ្យឱ្យបានច្បាស់លាស់ ដោយត្រូវមានឯកសារភស្តុតាងបញ្ជាក់ត្រឹមត្រូវ។ ក្នុងករណីសហគ្រាសពុំមានឯកសារភស្តុតាងបញ្ជាក់ត្រឹមត្រូវ ការកើនឡើងនូវគណនីទុនម្ចាស់ទ្រព្យត្រូវចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។

ឧទាហរណ៍៖ សហគ្រាស **ក** បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៅខែមករា ឆ្នាំ២០២០ ដែលមានដើមទុនចុះបញ្ជី ៦០០ លានរៀល ស្មើនឹង ១៥០ ០០០ ហ៊ុន (តម្លៃចារឹក ៤ ០០០ រៀល/ហ៊ុន) កាន់កាប់ភាគហ៊ុន ១០០% ដោយលោក **សុខ**។ ក្រោយពីដំណើរការអាជីវកម្ម សហគ្រាសមានការរីកចម្រើននិងដោយមានបំណងបង្កើនដើមទុនបន្ថែមដើម្បីពង្រីកអាជីវកម្ម នៅខែមករា ឆ្នាំ២០២៤ សហគ្រាសបានសម្រេចបោះចេញភាគហ៊ុនថ្មី



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

L202506130023TD3518

ចំនួន ២០០ ០០០ ហ៊ុន (តម្លៃចារឹក ៤ ០០០ រៀល/ហ៊ុន)។ ភាគហ៊ុនថ្មីនេះត្រូវបានបោះចេញទៅឱ្យលោក **សៅ** (ភាគហ៊ុនិកថ្មី) ក្នុងតម្លៃ ២ ០០០ លានរៀល (តម្លៃលក់ ១០ ០០០ រៀល/ហ៊ុន) ហើយលោក **សៅ** បានបង់ប្រាក់ទាំងស្រុងឱ្យសហគ្រាសតាមកិច្ចព្រមព្រៀងចូលហ៊ុននិងកាន់កាប់ភាគហ៊ុនថ្មី។

ករណីនេះ គណនីទុនម្ចាស់ទ្រព្យរបស់សហគ្រាសមានចំនួន ២ ៦០០ លានរៀល ដូចខាងក្រោម៖

- ដើមទុនចុះបញ្ជីដំបូង ៦០០ លានរៀល (១៥០ ០០០ ហ៊ុន x ៤ ០០០ រៀល/តម្លៃចារឹក ១ ហ៊ុន)
- ដើមទុនបន្ថែមថ្មី ២ ០០០ លានរៀល (២០០ ០០០ ហ៊ុន x ១០ ០០០ រៀល/ហ៊ុន) ដែលក្នុងនោះ៖
  - តម្លៃភាគហ៊ុនបោះថ្មី ៨០០ លានរៀល (២០០ ០០០ ហ៊ុន x ៤ ០០០ រៀល/តម្លៃចារឹក ១ ហ៊ុន)
  - បុព្វលាភភាគហ៊ុន ១ ២០០ លានរៀល (២០០ ០០០ ហ៊ុន x ៦ ០០០ រៀល/ហ៊ុន)។

ដូចនេះ បុព្វលាភភាគហ៊ុន (Share Premium) ចំនួន ១ ២០០ លានរៀល ដែលកើតឡើងតាមរយៈការបោះចេញភាគហ៊ុនថ្មី ដែលកាន់កាប់ដោយលោក **សៅ** គឺជាការបន្ថែមទុនរបស់ភាគហ៊ុនិកចូលទៅក្នុងដើមទុនរបស់សហគ្រាស មិនមែនជាប្រាក់ចំណូលជាប់ពន្ធទេ។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីជាអភិបាលឬបណ្ណាធិការរបស់សហគ្រាស ឬកម្មសិទ្ធិករទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**